# ១៧_រឿង ក្រុងឧត្តុង្គ ខេត្តកំពង់ស្ពឺ

ទីក្រុងឧត្តុង្គចាប់ផ្តើមសាងឡើងក្នុងសតវត្សទី១៧នៃគ.ស ក្នុងរជ្ជកាលព្រះបាទសម្តេចព្រះជ័យជេដ្ឋាទី២ ដូចមានចែងក្នុងព្រះរាជពង្សសាវតាប្រទេសកម្ពុជាតទៅនេះ

ក្នុងព.ស ២១៦៤ គ.ស ១៦៦០ព្រះបាទសម្តេចព្រះជ័យជេដ្ឋា ជាម្ចាស់ជីវិតលើត្បូង ស្តេចគង់នៅព្រះរាជវាំងល្វាឯម (សៀវភៅពង្សសាវតានៃប្រទេសកម្ពុជារបស់ក្រសួងសុខាធិការបោះពុម្ពផ្សាយក្នុងឆ្នាំ១៩៥២ ទំព័រ៩៥ ដាក់វង់ ក្រចកថា (ស្រុកព្រៃល្វាឯម)។ ទ្រង់នាំព្រះអគ្គមហេសីព្រះស្នំក្រំការ សេនាធិបតី និងនាម៉ឺនសព្វមុខមន្ត្រី ខុំរាជការទាំងពួងចុះព្រះរាជទីនាំងនាវា ស្តេចយាងទៅប្រពាតនៅតំបន់អូរក្រងលាយ ក្នុងខេត្តសំរោងទង ទ្រង់ប្រថាប់នៅព្រះពន្លាជាយូរថ្ងៃ រួចស្តេចយាងទៅក្រសាលនៅទីតាដុងយាយជ័យ ទ្រង់ទតឃើញទីទួលមួយនៅតំបន់ស្រះកែវ ជាទីមានទេសភាពល្អ ក៏ទ្រង់ចាប់ព្រះរាជហរទ័យ ហើយទ្រង់មានព្រះតម្រាស់និងមន្ត្រីខុំរាជការទាំងពួង មានហោរ៉ាធិបតីជាដើមថា "យើងចង់សាងព្រះរាជវាំងគង់នៅទីនេះ តើអស់លោកអ្នកទាំងពួងយល់ថាដូចម្តេច?"។ ឧកញ៉ាហោរ៉ាធិបតីគន់គូរពិនិត្យមើលទីដីនោះដោយក្បួនហោរ៉ាសាស្ត្រ ហើយក្រាបទូលថា "ទីនេះជាទីជយភូមិល្អណាស់ ត្រូវតាមក្បួនទាយថានឹងមានឫទ្ធិតបះតេជះឈ្នះអស់សត្រូវទាំង៨ទិស"។

ព្រះរាជាទ្រង់ជ្រាបដូច្នោះទ្រង់ចាត់ឱ្យកញ៉ាក្រឡាហោមកែវ ឱ្យជានាយកចាត់ការកសាងព្រះរាជវាំង នៅតំបន់ស្រះកែវនោះទ្រង់បាត់ហើយស្តេចត្រឡប់មកព្រះរាជវាំងល្វាឯមវិញ។

លំដាប់ពីនោះឧកញ៉ាក្រឡាហោមកែវ ក៏បង្គាប់ទៅចៅហ្វាយស្រុកឱ្យកេណ្ឌបណ្តារាស្ត្រ កាប់ដើមឈើ មកធ្វើជាព្រះរាជវាំងតាមព្រះរាជបញ្ជា។ លុះប្រមូលគ្រឿងសំភារៈបានសព្វគ្រប់ហើយ ឧកញ៉ាក្រឡាហោមកែវបង្គាប់មេការឱ្យចាប់ផ្តើមចាត់ការលើកដីធ្វើជាបន្ទាយយាមល្បាតជុំវិញសង់ជាព្រះរាជវាំង ព្រះរាជមន្ទីរ ព្រះរាជដំណាក់តូច ដំណាក់ធំ និងចុងព្រះរាជរោងប្រមាណ១០ខែទើបរួចស្រេច ហើយយកសេចក្តីក្រាបបង្គំទូល សូមទ្រង់ជ្រាបសព្វ គ្រប់ការ ។ លុះទ្រង់ជ្រាបហើយ ព្រះបាទសម្តេចជ័យជេដ្ឋាជាម្ចាស់ជីវិតលើត្បូង ស្តេចចាកចេញពីព្រះបរមរាជវាំងល្វាឯម ទ្រង់ឡើងគង់ព្រះទីនាំងនាវា ធ្វើព្រះរាជដំណើរតាមទន្លេសាបមួយអន្លើ ដោយព្រះរាជអគ្គមហេសី ព្រះស្នំក្រំការ ព្រះរាជាវង្សានុវង្ស សេនាធិបតី នាម៉ឺនសព្វមុខមន្ត្រីខុំរាជការ គ្រប់ក្រុមរាជាបរិពារ ដល់កំពង់តាដុងយាយជ័យ ប្រថាប់នៅទីនោះ៣រាត្រី ទ្រង់ព្រះរាជបញ្ញត្តិឱ្យហៅទីនោះថា កំពង់ហ្លួង ហើយទ្រង់ព្រះរាជបញ្ជាភ្នាក់ងារមុខក្រសួង ឱ្យរៀបចំធ្វើព្រះរាជពិធីឡើងព្រះរាជវាំងថ្មី និមន្តព្រះរាជាគណចំរើនព្រះបរិត្ត៣ថ្ងៃ ចូលព្រះរាជពិធី នៅថ្ងៃ៥កើតខែផល្គុន ឆ្នាំរកទោស័ក ព.ស ២១៦៤ គ.ស ១៦២០ ហើយព្រះរាជវង្សានុវង្ស ព្រះអគ្គមហេសី ព្រះស្នំក្រំការ សេនាធិបតី មន្ត្រីខុំរាជការជាបរិពារហែស្តេចឡើងកំពង់ហ្លួង ចូលទៅគង់ព្រះរាជវាំងថ្មី រួចទ្រង់ឱ្យរៀបធ្វើព្រះរាជពិធីសម្ពោធ ព្រះនគរ៣ថ្ងៃដោយមានល្បែងមហោស្រព គ្រប់បែបជាឧឡារិក អធិកអធមក្រៃពេក ទើបទ្រង់តាំងព្រះនាមនគរ (ទីក្រុង) ថ្មីនោះថា "ព្រះបរមរាជវាំងមហានគរ ឧត្តុង្គមានជ័យបុរីរម្យ ឧត្តមរាជនិវេសដ្ឋាន" ដែលហៅខ្លីថា "ក្រុងឧត្តុង្គមានជ័យ" ។